# ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៤៣

## ស្តីពី
## ការកែសម្រួល និងការធ្វើនិយតភាព
## ការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ភោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/0៩0៨/១0៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២00៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២0 ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0១៩៦/0៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0៦៩៩/0៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់សេចក្តីសំរេចលេខ ៣១៩/៨0 ក.ប ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៨0 របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានកែសម្រួល និងធ្វើនិយតភាព សេចក្តីសំរេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជាព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដែលហៅជាអក្សរកាត់ថា " **គ.ជ.ទ.ម.ក** " និងជាភាសាអង់គ្លេស សរសេរថា "Cambodia National Mekong Committee" ដែលហៅជាអក្សរកាត់ថា " **CNMC** " ជាស្ថាប័នជាតិមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល សម្រាប់សម្របសម្រួល ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ២
## សមាសភាព

**មាត្រា ២.-** គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសមាសភាពដូចតទៅ :

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់មួយចំនួន | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី ០១ រូប | សមាជិក |
| - អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - អគ្គលេខាធិការអាជ្ញាធរទន្លេសាប | សមាជិក |

ការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៣
## ភារៈរៀបចំ និង ការប្រព្រឹត្តទៅ
## របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

**មាត្រា ៣.-**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានមុខងារ និងភារកិច្ច ដូចតទៅ:

- ជាសេនាធិការជំនួយការឱ្យរាជរដ្ឋាភិបាល សម្រាប់សម្របសម្រួល ក្នុងការគ្រប់គ្រង ការពិនិត្យពិចារណា ការសិក្សា ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីបុព្វហេតុសេដ្ឋកិច្ចប្រទេសជាតិ និងផលប្រយោជន៍របស់ប្រជាជន និងបុព្វហេតុសន្តិភាព មិត្តភាព និងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើការសិក្សាពិនិត្យពិចារណា ហើយលើកសំណើ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចលើរាល់បញ្ហាទាំងឡាយណា ដែលទាក់ទងនឹងការធ្វើផែនការ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ស្តីពីការគ្រប់គ្រង ការថែរក្សា ការពារ និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព

Downloaded from http://www.khmerlaws.com

- សម្របសម្រួល និងសហការជាមួយ ក្រសួង-ស្ថាប័នជាតិ ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព
- រួមសហការជាមួយ ក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសំរេចទាំងឡាយ របស់រាជរដ្ឋាភិបាល ស្តីពីអាងទន្លេមេគង្គ
- ពង្រឹងសហប្រតិបត្តិការ ជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិក គណៈកម្មការទន្លេមេគង្គ ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិផ្សេងៗ ក្នុងការពិនិត្យពិចារណា ការសិក្សា ការអភិវឌ្ឍ ការគ្រប់គ្រង និងការថែរក្សាធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គឱ្យបានសមស្របទៅនឹងផលប្រយោជន៍ដ៏សមរម្យ របស់បណ្តាប្រទេសជាសមាជិក និងដោយត្រឹមត្រូវ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីអាងទន្លេមេគង្គ
- ធ្វើទំនាក់ទំនង សម្របសម្រួល ជាមួយគណៈកម្មការទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកទុនជំរុញការសិក្សា និងការអភិវឌ្ឍគំរោងឱ្យបានឆាប់រហ័ស ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- កៀងគររកមធ្យោបាយ និងធនធាន ដើម្បីរួមចំណែក ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងវិស័យធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ដល់អ្នកពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**មាត្រា ៤.-**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដឹកនាំដោយប្រធានមួយរូប ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធានមួយចំនួន មានឋានៈយ៉ាងទាបស្មើរដ្ឋលេខាធិការ ក្នុងនោះមួយរូបជាអនុប្រធានអចិន្ត្រៃយ៍ និងទីប្រឹក្សាមួយចំនួន ជាជំនួយការ ។

**មាត្រា ៥.-**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាព ដូចតទៅ:

- ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប្រធាន
- អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អនុប្រធាន
- អគ្គលេខាធិការនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
- អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក ។

**មាត្រា ៦.-**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានអគ្គលេខាធិការដ្ឋានមួយ ដឹកនាំដោយអគ្គលេខាធិការ មានឋានៈស្មើរដ្ឋលេខាធិការ អមដោយអគ្គលេខាធិការរងមួយចំនួន មានឋានៈស្មើអនុរដ្ឋលេខាធិការ ជាជំនួយការ ។

Downloaded from http://www.khmerlaws.com

**មាត្រា ៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨.-**

សមាសភាពគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍មានសិទ្ធិពេញលេញ ក្នុងការដឹកនាំការងាររបស់គណៈកម្មាធិការ ជាតិទន្លេមេគង្គកម្ពុជា តាមការប្រគល់សិទ្ធិរបស់ប្រធាន ។ ក្នុងករណីប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ អវត្តមាន ប្រធានត្រូវប្រគល់សិទ្ធិ ជូនអនុប្រធានណាមួយ ។

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ នៃក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធនានា ឬ ឥស្សរជន ដែលមានបទពិសោធន៍ និងសមត្ថភាពខ្ពស់ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន។

**មាត្រា ៩.-**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រាដាច់ដោយឡែករបស់ខ្លួន។

**មាត្រា ១០.-**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និងកញ្ចប់ថវិកាដោយឡែក ជាឧបសម្ព័ន្ធរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

## ជំពូកទី ៤
## ប្រភពធនធានថវិកា

**មាត្រា ១១.-**

ប្រភពធនធានថវិការបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី :

- ថវិកាជាតិ ជាកញ្ចប់ដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ របស់ក្រសួងធនធានទឹក និងឧតុនិយម
- អំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍន៍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណង ឬ កម្ចី ដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពខាងក្នុង ឬ ក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

ព្រះរាជក្រឹត្យនេះ ជំនួសសេចក្តីសំរេចលេខ ៣១៩/៨០ ក.ប ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបាននិរាករណ៍ ។

**មាត្រា ១៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០០៩*

នស/រកត.០៩០៩.៩៤០ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៨៨៥ ច.ល

ចម្លងចេញពីច្បាប់ដើម ថតចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

Downloaded from http://www.khmerlaws.com